# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## ស ម្រេ ច

### មាត្រា ១.-

ត្រូវបានបង្កើតពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា ( PREAH SIHAMONI RAJA BUDDHIST UNIVERSITY) ហៅកាត់ជាភាសាខ្មែរ "ព.ស.ស.រ." និងហៅកាត់ជាភាសាអង់គ្លេស " P.S.B.U. " ។ ពុទ្ធិកសាកលវិទ្យាល័យនេះ ស្ថិតនៅក្រោមឱវាទ អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ២.-

ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា មានតួនាទី និងភារកិច្ចអប់រំ បណ្តុះបណ្តាលសមណនិស្សិត និងនិស្សិត សិក្សាស្រាវជ្រាវ ពុទ្ធសាសនា និងសាសនាឯទៀត វប្បធម៌ អក្សរសាស្ត្រ វិទ្យាសាស្ត្រសង្គម និងព័ត៌មានវិទ្យា ។

### មាត្រា ៣.-

ចំពោះមុខ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា ធ្វើការបណ្តុះបណ្តាល កម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ។ កម្មវិធីសិក្សា ត្រូវមានការឯកភាព ពីក្រសួងអប់រំ យុវជន និងកីឡា ។

### មាត្រា ៤.-

ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា ដឹកនាំដោយសាកលវិទ្យាធិការមួយរូប ជាមន្ត្រីសង្ឃជាន់ខ្ពស់ គណៈធម្មយុត្ត ដែលមានសមត្ថភាពសមស្រប និងសាកលវិទ្យាធិការរងមួយរូប ឬច្រើនរូប ជាជំនួយការ ដែលជាមន្ត្រីសង្ឃ ឬជាគ្រហស្ថ ។

### មាត្រា ៥.-

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា ត្រូវកំណត់ដោយប្រកាស របស់ក្រសួងធម្មការ និងសាសនា តាមរយៈអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ៦.-

ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា មានពុទ្ធិកមហាវិទ្យាល័យចំនួនបួន (៤) និងពុទ្ធិកមជ្ឈមណ្ឌល គរុកោសល្យចំនួនមួយ (១) ដូចខាងក្រោម :

- ពុទ្ធិកមហាវិទ្យាល័យទស្សនវិជ្ជា សាសនា និងនីតិសាស្ត្រ
- ពុទ្ធិកមហាវិទ្យាល័យបាលី-សំស្ក្រឹត និងភាសាបរទេស
- ពុទ្ធិកមហាវិទ្យាល័យវិទ្យាសាស្ត្រអប់រំ និងអក្សរសាស្ត្រ
- ពុទ្ធិកមហាវិទ្យាល័យព័ត៌មានវិទ្យា ។

នៅអនាគត ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា អាចមានពុទ្ធិកមហាវិទ្យាល័យ ឯកទេស សាខា ឬ ពង្រីកកម្រិត ឬប្រភេទបណ្តុះបណ្តាលផ្សេងទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាត ពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៧.-**

សមណនិស្សិត និងនិស្សិតដែលរៀនចប់កម្មវិធីសិក្សា របស់ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា និងទទួលបានជោគជ័យក្នុងការប្រលងបញ្ចប់ការសិក្សា ទទួលសញ្ញាបត្រតាមកម្រិត និងតាមឯកទេស ដែលបានសិក្សា ។ សញ្ញាបត្រនេះ ផ្តល់ឱ្យដោយ ពុទ្ធិកសាកលវិទ្យាល័យព្រះសីហមុនីរាជា អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីពុទ្ធិកសាកលវិទ្យាល័យនេះ បំពេញ និងអនុវត្តបានតាមគោលការណ៍ និងបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៨.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី និងរដ្ឋលេខាធិការនៃក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០០៧

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

កន្លែងទទួល

- ខុទ្ទកាល័យសម្តេចព្រះសង្ឃរាជទាំងពីរគណៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលាក្រុងភ្នំពេញ
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ -កាលប្បវត្តិ